**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ៣៧/២០ ព.ណ.ភណប

ថ្ងៃពុធ ៧រោច ខែ មិគសិរ ឆ្នាំខាលចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែ ធ្នូ ឆ្នាំ ២០២២

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្មមានកិត្តិយស សូមជម្រាបជូនដំណឹងដល់ លោក លោកស្រី អ្នកនាង កញ្ញា ទាំងអស់ដែលជាភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជា ឬ/និង កន្លងមកទទួលបានជោគជ័យក្នុងការបណ្តុះបណ្តាល ធ្វើជាភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជា សូមមកបង់កម្រៃសមាជិកភាពរបស់ខ្លួនប្រចាំឆ្នាំ ដើម្បីក្លាយជាភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកដែលទទួលស្គាល់ជាផ្លូវការសម្រាប់ឆ្នាំ២០២៣ យោងតាមប្រកាសលេខ ០៤៥ MOC/SM 2011 ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពីភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជា និងប្រកាសអន្តរក្រសួង ស្តីពី ការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រី អ្នកនាង កញ្ញា ទាញយកគំរូពាក្យស្នើសុំចុះឈ្មោះដូចបានជូនភ្ជាប់។ ពាក្យស្នើសុំត្រូវដាក់នៅបញ្ជរនៃនាយកដ្ឋានកម្មសិទ្ធិបញ្ញា និងត្រូវបង់កម្រៃសមាជិកភាពរបស់ខ្លួនដើម្បីក្លាយជាភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកដែលទទួលស្គាល់ជាផ្លូវការសម្រាប់ឆ្នាំ២០២៣ នៅបញ្ជរបង់ប្រាក់រួមរបស់ក្រសួងពាណិជ្ជកម្ម រៀងរាល់ម៉ោងធ្វើការ **ចាប់ពីថ្ងៃផ្សព្វផ្សាយជូនដំណឹងនេះរហូតដល់ ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៣។**

សូមអរគុណ!

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

ទម្រង់ឆ្នាំ២០២៣

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

### ពាក្យស្នើសុំចុះឈ្មោះ
### ទទួលស្គាល់ជាផ្លូវការ ជាភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជា និង
### ជីវប្រវត្តិសង្ខេប

**១. ជីវប្រវត្តិសង្ខេបរបស់អ្នកស្នើសុំ៖**

-គោត្តនាម និងនាមខ្លួន.......................................អក្សរឡាតាំង.......................................................

- ភេទ.................សញ្ជាតិ..................ថ្ងៃខែឆ្នាំកំណើត.............../................./.............................

- ទីកន្លែងកំណើត.........................................................................................................................

- អាសយដ្ឋានបច្ចុប្បន្ន...................................................................................................................

-លេខទូរស័ព្ទ............................................អ៊ីម៉ែល.......................................................................

-កម្រិតវប្បធម៌ទូទៅ.......................................................................................................................

-កម្រិតជំនាញ................................................................................................................................

- ភាសាបរទេស និងកម្រិតនៃការយល់ដឹង.........................................................................................

- ស្ថានភាពគ្រួសារ៖ ☐ នៅលីវ ☐ មានគ្រួសារ

- ឪពុកឈ្មោះ................................... (រស់ ☐ ឬ ☐ ស្លាប់) មុខរបរ....................................................

- ម្ដាយឈ្មោះ.................................. (រស់ ☐ ឬ ☐ ស្លាប់) មុខរបរ....................................................

- មុខរបរបច្ចុប្បន្ន............................................................................................................................

- បទពិសោធន៍ការងារកន្លងមក........................................................................................................

**២.ឈ្មោះនីតិបុគ្គលដែលបាន/និងបម្រើការងារ៖**...........................................................................

- អាសយដ្ឋានទំនាក់ទំនង៖.............................................................................................................

-លេខទូរស័ព្ទ៖............................................អ៊ីម៉ែល៖.....................................................................

**៣.វិញ្ញាណបនបត្របញ្ជាក់ជាភ្នាក់ងារតំនាងស្របច្បាប់នៃម្ចាស់ម៉ាក លេខ៖......................ចុះថ្ងៃទី៖.....................**

**៤. ឯកសារភ្ជាប់៖**

- ច្បាប់ដើម ឬចម្លងវិញ្ញាណបនបត្របញ្ជាក់ទទួលស្គាល់ជាភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក
- ច្បាប់ចម្លងនីតិបុគ្គល
- ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន
- សេចក្ដីប្រកាសពុំមានទំនាស់ផលប្រយោជន៍ និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

ថ្ងៃ ខែ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២....

ហត្ថលេខា និងឈ្មោះ

ទម្រង់ឆ្នាំ២០២៣

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

### សេចក្តីប្រកាសពុំមានទំនាស់ផលប្រយោជន៍ និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ..................................... ភេទ.............. កើតថ្ងៃទី.......... ខែ............. ឆ្នាំ................
កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ............................................ បច្ចុប្បន្នជា.........................................
ដែលមានអាសយដ្ឋាននៅ.............................................................................................................................
ទូរស័ព្ទលេខ............................................................. អ៊ីម៉ែល...............................................................

**សូមប្រកាស និងអះអាងចំពោះមុខច្បាប់ថា៖**

ខ្ញុំបាទ/នាងខ្ញុំ ពុំមែនជាមន្ត្រីរាជការបម្រើក្នុងក្រសួង ឬស្ថាប័នរដ្ឋណាមួយឡើយ ហើយមិនដែលត្រូវបានជាប់ទោសពៃរ៍ណាមួយទោះព្រហ្មទណ្ឌ រដ្ឋប្បវេណី ឬរដ្ឋបាលក្តីក្នុងព្រះរាជាណាចក្រកម្ពុជា និងពុំមានទំនាស់ផលប្រយោជន៍ណាមួយឡើយ។ ជាងនេះទៅទៀត ខ្ញុំបាទ/នាងខ្ញុំសូមអះអាងថា ខ្ញុំបាទ/នាងខ្ញុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ស្របតាមច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងប្រកាសស្តីពី ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជា។

ក្នុងករណីដែលសេចក្តីប្រកាសនេះមិនត្រឹមត្រូវតាមការពិត ខ្ញុំបាទ/នាងខ្ញុំសូមទទួលខុសត្រូវទាំងស្រុងនៅចំពោះមុខច្បាប់ជាធរមាន។

ថ្ងៃ ខែ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២....
ស្នាមមេដៃស្តាំ និងឈ្មោះ